# ចម្លើយសម្រាប់ការសម្ភាសន៍ស្តីពីបុរាណវិទ្យានៅស្រុកខ្មែរ

១- មុនដំបូង តើមានរឿងអ្វីខ្លះធ្វើឱ្យអ្នកចាប់អារម្មណ៍នឹងបុរាណវិទ្យានៅស្រុកខ្មែរ?
ចម្លើយ៖ កាលដើមឡើយ (មុនពេលចូលរៀននៅមហាវិទ្យាល័យបុរាណវិទ្យា) ខ្ញុំពុំមានចំណាប់អារម្មណ៍នឹងបុរាណវិទ្យាទេ។ ក្រោយមក អ្វីដែលនាំឱ្យចាប់អារម្មណ៍លើបុរាណវិទ្យាគឺការចង់យល់ដឹងអំពីសំណល់ប្រាង្គប្រាសាទជាច្រើនដែលមាននៅក្នុងស្រុកកំណើតរបស់ខ្ញុំ។

២- តើអ្នកធ្លាប់រៀនអំពីបុរាណវិទ្យានៅសាលាមធ្យមសិក្សា ឬអនុវិទ្យាល័យទេ? រៀនអំពីអ្វីខ្លះ?
ចម្លើយ៖ កាលខ្ញុំរៀននៅសាលាមធ្យមសិក្សា ទាំងបឋមភូមិ (អនុវិទ្យាល័យ) និងទុតិយភូមិ (វិទ្យាល័យ) ពុំមានមុខវិជ្ជាបុរាណវិទ្យាទេ។ ប៉ុន្តែ នៅក្នុងកម្មវិធីសិក្សា ក្រសួងអប់រំ យុវជន និងកីឡាបានបញ្ច្រាបផ្នែកខ្លះនៃប្រវត្តិសិល្បៈ និងប្រវត្តិសាស្ត្រខ្មែរចូលទៅក្នុងមុខវិជ្ជាទស្សនវិជ្ជា។ ឧទាហរណ៍៖ ប្រវត្តិសង្ខេបនៃព្រះមហាក្សត្រខ្មែរ រចនាបថសិល្បៈខ្មែរ លទ្ធិសាសនា ។ល។

៣- ហេតុអ្វីបានជាអ្នកសម្រេចចិត្តរៀននៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ? សូមអធិប្បាយ។
ចម្លើយ៖ តាមពិតទៅ ខ្ញុំពុំមានគោលដៅចូលរៀននៅសាកលវិទ្យាល័យភុមិន្ទវិចិត្រសិល្បៈទេ។ ក្រោយពេលប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឪពុកម្តាយរបស់ខ្ញុំចង់ឱ្យខ្ញុំរៀនបន្ត ហើយពួកគាត់បានបញ្ជូនខ្ញុំមកទីក្រុងភ្នំពេញ ដើម្បី ប្រលង ចូល មហាវិទ្យាល័យ។ ខ្ញុំ បាន ដាក់ ពាក្យ ប្រលង ចូល មហាវិទ្យាល័យ ៤ខុស។ គ្នា៖ មហាវិទ្យាល័យនីតិសាស្ត្រ មហាវិទ្យាល័យទន្តសាស្ត្រ សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ និងមហាវិទ្យាល័យបុរាណវិទ្យា។ ជាលទ្ធផល សំណាងល្អ ខ្ញុំប្រលងជាប់តែមហាវិទ្យាល័យបុរាណវិទ្យាមួយប៉ុណ្ណោះ។ ដោយសារគ្មានជម្រើសទើបខ្ញុំសម្រេចចិត្តរៀននៅក្នុងមហាវិទ្យាល័យនេះ។ ទោះបីជាយ៉ាងណា ខ្ញុំសប្បាយរីករាយនឹងចូលរៀននៅក្នុងសាលានេះ ហើយក្រោយពេលចូលរៀនបាន៦ខែ ខ្ញុំរឹតតែចូលចិត្តបុរាណវិទ្យាខ្លាំងឡើង។។

៤- តើអ្នកមានបំណងធ្វើការជាបុរាណវិទូអាជីពដែរទេ?
ចម្លើយ៖ ប្រាកដណាស់ កាលនៅជានិស្សិតបុរាណវិទ្យា ខ្ញុំមានបំណងធ្វើជាបុរាណវិទូអាជីពម្នាក់។ ការចូលរួមក្នុងកម្មសិក្សារបស់សាលា និងកម្មវិធីបណ្តុះបណ្តាលអំពីបុរាណវិទ្យារៀបចំដោយក្រុមបុរាណវិទ្យាអន្តរជាតិនានានៅតាមខេត្តផ្សេងៗ ក៏ដូចជានៅបរទេសរឹតតែជម្រុញឱ្យខ្ញុំកាន់តែមានក្តីរំពឹងច្រើនឡើងក្នុងការក្លាយខ្លួនទៅជាបុរាណវិទូអាជីព។ តែជាអកុសល ក្រោយពេលបញ្ចប់បរិញ្ញាប័ត្របុរាណវិទ្យា ការរំពឹងទុករបស់ខ្ញុំគ្រាន់តែជាការយល់សប្តិប៉ុណ្ណោះ។ មានកត្តាច្រើនយ៉ាងដែលនាំឱ្យសុបិន្តរបស់ខ្ញុំមិនអាចក្លាយជាការពិត៖ ទីជម្រករការងារ សមត្ថភាពយល់ដឹងនៅមានកម្រិត គ្មានឱកាសពង្រីកចំណេះដឹងដែលមានស្រាប់ ។ល។

៥. តើអ្នកមានបំណងរៀនបុរាណវិទ្យានៅសាកលវិទ្យាល័យក្រៅប្រទេសឬទេ?
ចម្លើយ៖ ពិតប្រាកដណាស់ ខ្ញុំតែងតែមានបំណងបន្តរៀនបុរាណវិទ្យានៅបរទេស។

៦. អ្នកគិតថាមនុស្សខ្មែរគិតថាបុរាណវិទ្យានៅស្រុកខ្មែរសំខាន់ទេ? សម្រាប់ប្រជាជនខ្មែរ តើបុរាណវិទ្យាជារឿងសំខាន់ទេ? សូមអធិប្បាយ។
ចម្លើយ៖ ក្រៅពីនិស្សិតបុរាណវិទ្យា និងមនុស្សមួយចំនួនដែលយល់ពីបុរាណវិទ្យា ខ្ញុំមិនគិតថាមនុស្សខ្មែរគិតថាបុរាណវិទ្យា នៅស្រុកខ្មែរសំខាន់ទេ។ សម្រាប់ប្រជាជនខ្មែរ បុរាណវិទ្យាប្រហែលមិនមែនជារឿងសំខាន់ទេ ព្រោះប្រជាជនខ្មែរស្ទើរតែទាំងអស់ពុំស្គាល់ ឬយល់ពីបុរាណវិទ្យាទេ។ ទោះបីជាយ៉ាងណា គេគ្រាន់តែដឹងថាវត្ថុសិល្ប: និងប្រាង្គប្រាសាទទាំងឡាយដែលមាននៅស្រុកខ្មែរជាកេរតំណែលពីបុរាណកាលមកប៉ុណ្ណោះ។ ប៉ុន្តែគេពុំយល់អំពីតម្លៃនៃសំណល់វត្ថុបុរាណដែលកប់នៅក្នុងដី ទីតាំងស្ថានីយបុរាណ និងសំណល់គ្រិះប្រាសាទបាក់បែកដែលមាននៅស្រុកខ្មែរទេ។ ហេតុដូច្នេះហើយទើបមនុស្សភាគច្រើនព្យាយាមលួចជីកគ្រិះប្រាសាទ ជីកទីតាំងផ្នូរបុរាណ ពង្រាបបណ្តាញផ្លូវ និងទំនប់ទឹកបុរាណ ។ល។ ដើម្បីបំពេញបំណងដែលគេត្រូវការ ដោយពុំគិតថាសកម្មភាពដែលពួកគេធ្វើគឺជាការបំផ្លាញភស្តុតាងបុរាណវិទ្យានៅស្រុកខ្មែរឡើយ។ លើសពីនេះ ការអភិវឌ្ឍន៍ផ្សេងៗក្នុងស្រុកខ្មែរ គេធ្វើឡើងដោយពុំបានគិតដល់ការប៉ះពាល់ និងការបំផ្លាញសំណល់បុរាណឡើយ។

៧. តាមយោបល់អ្នក តើហេតុអ្វីស្រុកខ្មែរមានបញ្ហាលួចវត្ថុបុរាណ? តើអ្នកគិតថាយើងអាចប្រើវិធីអ្វីដើម្បីដោះស្រាយបញ្ហានេះ?
ចម្លើយ៖ ស្រុកខ្មែរមានបញ្ហាលួចវត្ថុបុរាណដោយសារមូលហេតុច្រើនយ៉ាងដែលមានទាក់ទងគ្នាទៅវិញទៅមក។ បញ្ហាទាំងនោះមានដូចជា៖ ចរាចរណ៍ទិញ-លក់វត្ថុបុរាណក្នុងតម្លៃខ្ពស់ ការមិនយល់តម្លៃនិងភាពល្ងង់ខ្លៅរបស់ប្រជាជន ភាពក្រីក្រនិងអត់ឃ្លាន ភាពគ្មានការងារធ្វើនិងគ្មានចំណូលសម្រាប់គ្រួសារ ។ល។ ការដោះស្រាយបញ្ហាទាំងនេះអាចធ្វើទៅបានអាស្រ័យដោយមានការចូលរួមសហការគ្នារវាងរដ្ឋាភិបាល និងប្រជាជន។ ការបិទនិងលុបបំបាត់ទីផ្សារនិងចរាចរណ៍ទិញ-លក់វត្ថុបុរាណគ្រប់ប្រភេទប្រកបដោយប្រសិទ្ធិភាព ការបង្ករលក្ខណ:ងាយស្រួលដល់ជីវភាពរស់នៅរបស់ប្រជាជនតាមរយ:ការផ្តល់ការងារធ្វើនិងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសាធារណ: និងការអប់រំផ្សព្វផ្សាយជាវិធីដែលអាចប្រើសម្រាប់ដោះស្រាយបញ្ហាលួចវត្ថុបុរាណនៅស្រុកខ្មែរ។

៨. តើអ្នកគិតថាអំពើរបស់បុរាណវិទូបរទេសមានជួយស្រុកខ្មែរ ឬបង្កើតបញ្ហានៅស្រុកខ្មែរ? សូមអធិប្បាយ។
ចម្លើយ៖ ខ្ញុំគិតថា សកម្មភាពរបស់បុរាណវិទូបរទេសនៅស្រុកខ្មែរមានទាំងជួយស្រុកខ្មែរ និងទាំងបង្កើតបញ្ហានៅស្រុកខ្មែរ។ ជំនួយរបស់បុរាណវិទូបរទេសមកស្រុកខ្មែរនោះមានច្រើន៖ ការបណ្តុះបណ្តាលនិស្សិតខ្មែរអំពីបុរាណវិទ្យានៅមហាវិទ្យាល័យបុរាណវិទ្យា ការបញ្ជូននិស្សិតបញ្ចប់បរិញ្ញាប័ត្រទៅបន្តការសិក្សានៅបរទេស

ការរួមចំណែកស្រាវជ្រាវអំពីស្ថានីយបុរាណប្រយោជន៍លើកស្ទួយវិស័យបុរាណវិទ្យានៅស្រុកខ្មែរ  ការចុះបញ្ជីសារពើភ័ណ្ឌការធ្វើកំណាយស្រាវជ្រាវស្ថានីយបុរេប្រវត្តិសាស្ត្រនានា ការផ្តល់ឱកាសពង្រីកបទពិសោធន៍តាមរយៈការអនុវត្តន៍ការងារជាមួយស្ថាប័នអន្តរជាតិដែលធ្វើការស្រាវជ្រាវនៅក្នុងស្រុកខ្មែរ ។ល។ ទន្ទឹមនឹងជំនួយទាំងប៉ុន្មានខាងលើ ស្រុកខ្មែរក៏ប្រឈមមុខនឹងបញ្ហាមួយចំនួនដែរ។ បញ្ហាទាំងនោះមាន៖ ការប្រកាន់ខ្ជាប់នូវបច្ចេកទេសដែលទទួលបានពីក្រុមបុរាណវិទូបរទេសផ្សេងគ្នា ការកាន់កាប់ផ្តាច់មុខនៃក្រុមបុរាណវិទូបរទេសនូវតំបន់ ឬទីតាំងស្រាវជ្រាវ បុរាណវិទូខ្មែរពុំទាន់អាចអនុវត្តការស្រាវជ្រាវដោយឯករាជ្យបានក្នុងពេលវត្តមានបុរាណវិទូបរទេស ។ល។ ទោះបីជាយ៉ាងណា បញ្ហាទាំងអស់នេះពុំបង្ករឱ្យមានភាពស្មុគ្រស្មាញច្រើនដល់វិស័យបុរាណវិទ្យាខ្មែរទេ។

៩_ តើបុរាណវិទូបរទេសអាចធ្វើអ្វីខ្លះដើម្បីជួយស្រុកខ្មែរ?

ចម្លើយ៖ ខ្ញុំគិតថា អ្វីដែលបុរាណវិទូបរទេសគួរធ្វើដើម្បីជួយស្រុកខ្មែរគឺ៖ ផ្តល់នូវការបណ្តុះបណ្តាលរយៈពេលវែងទាក់ទងនឹងវិស័យបុរាណវិទ្យាដល់និស្សិតនៅមហាវិទ្យាល័យបុរាណវិទ្យា បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវអចិន្ត្រៃយ៍សម្រាប់ការងារទាក់ទងនឹងបុរាណវិទ្យាសហប្រតិបត្តិការយ៉ាងជិតស្និទជាមួយបុរាណវិទូខ្មែរក្នុងការលើកគំរោងស្រាវជ្រាវផ្សេងៗ និងបង្កើតឱ្យមានកម្មវិធីសិក្សាផ្លាស់ប្តូរនិស្សិតបុរាណវិទ្យាខ្មែរនិងបរទេសសម្រាប់វិស័យបុរាណវិទ្យា។

១០_ តើអ្នកគិតថា បុរាណវិទ្យាអាចជួយនូវការអភិវឌ្ឍន៍នៅស្រុកខ្មែរ?

ចម្លើយ៖ បាទ ខ្ញុំគិតថាបុរាណវិទ្យាជាចំណែកមួយដែលអាចជួយដល់ការអភិវឌ្ឍន៍នៅស្រុកខ្មែរ។ បើទោះជាមិនច្រើន ក៏ជួយបានមួយចំណែកតូចដែរ។ ខ្ញុំសូមលើកឧទាហរណ៍មួយដែលបង្ហាញថាបុរាណវិទ្យាអាចរួមចំណែកក្នុងការអភិវឌ្ឍន៍ស្រុកខ្មែរ៖ ប្រសិនបើវិស័យបុរាណវិទ្យាខ្មែររីកចម្រើន ហើយមានការជួយគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋាភិបាល យើងអាចប្រើវិស័យនេះសម្រាប់ទាក់ទាញទេសចរមកទស្សនា ជាពិសេស តំបន់ដែលមានស្ថានីយបុរេប្រវត្តិសាស្ត្រ ឬទ្បបុរាណ។ មជ្ឈមណ្ឌលស្រាវជ្រាវបុរាណវិទ្យាដែលបង្កើតឡើងអាចជាទីតាំងមួយសម្រាប់បង្កើតសារមន្ទីរបុរាណវិទ្យានៅក្នុងតំបន់សម្រាប់តាំងបង្ហាញនូវរាល់វត្ថុសិល្បៈដែលរកឃើញតាមរយៈការធ្វើកំណាយ ហើយវត្ថុទាំងអស់នោះនឹងទាក់ទាញភ្ញៀវទេសចរមកទស្សនា។ ការមកដល់របស់ភ្ញៀវទេសចរអាចផ្តល់នូវការងារមួយចំនួនដល់ប្រជាជនដែលរស់នៅក្នុងតំបន់ ដែលនេះជាចំណែកមួយអាចជួយកាត់បន្ថយភាពក្រីក្ររបស់ពួកគាត់។ សារមន្ទីរនេះក៏អាចក្លាយជាកន្លែងសម្រាប់បណ្តុះបណ្តាលកុមារ និងប្រជាជនក្នុងតំបន់សម្រាប់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ ក៏ដូចជាវិស័យបុរាណវិទ្យាដែលនេះជាចំណែកមួយក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងតំបន់។